អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ក្រុមសំអាត

អ្នកនិពន្ធ៖ លី ហាន់ណាហ្វី
រូបភាពដោយ៖ សែម រ៉ាស៊ីន





វ៉ាយុទ្ធជាក្មេងរស់នៅទីជនបទ។ គាត់ជាកុមារាម្នាក់ដែលមានសណ្ដាប់ធ្នាប់និងអនាម័យល្អ
ហើយគាត់តែងតែជួយការងារផ្ទះម្ដាយគាត់ជារៀងរាល់ថ្ងៃ។





វ៉ាយុទ្ធតែងតែដើរទៅសាលារៀនជារៀងរាល់ព្រឹក។

នៅតាមផ្លូវវ៉ាយុទ្ធបានជួបនឹងមិត្តរួមថ្នាក់ម្នាក់ឈ្មោះ សំណាង។



សំណាងបានបោះសំរាមចោលតាមផ្លូវពេលដែលគាត់កំពុង
ធ្វើដំណើរទៅសាលារៀនជាមួយឪពុកគាត់។




វ៉ាយុទ្ធបានឃើញបែបហ្នឹង ហើយក៏រើសសំរាមនោះ ដើម្បីបោះចោលនៅសាលារៀន ព្រោះតាមផ្លូវគ្មានធុងសំរាមទេ។ ជារៀងរាល់ព្រឹក វ៉ាយុទ្ធតែងតែរើសសំរាមតាមដងផ្លូវបានយ៉ាងច្រើន ទម្រាំគាត់ដើរទៅដល់ថ្នាក់រៀន។ ដៃរបស់គាត់កាន់សុទ្ធតែសំរាម។



ពេលវ៉ាយុទ្ធទៅដល់សាលារៀន មិត្តរបស់គាត់តែងតែសើចចំអកឱ្យគាត់ ហើយហៅគាត់ថា ក្មេងសំរាម។
វ៉ាយុទ្ធមិនសប្បាយចិត្តហើយថែមទាំងយំទៀតផង។




ថ្ងៃមួយ អ្នកគ្រូបង្រៀនក្មេងៗទាំងអស់ពីមេរៀនមួយដែលនិយាយពីផលប៉ះពាល់របស់សំរាមនិងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។



អ្នកគ្រូបាននិយាយប្រាប់កុមារទាំងអស់គ្នាថា ការចោលសំរាមតាមដងផ្លូវផ្តេសផ្តាសធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ខ្យល់មានជាតិពុល បំពុលទឹកនិងដីគ្មានជីជាតិ។




អ្នកគ្រូសួរក្មេងៗ ‹‹តើកូនៗចូលចិត្តសំរាមដែរឬទេ? តើកូនៗចង់ឃើញសំរាមនៅពាសពេញដី ក្នុងទឹកដែរឬទេ?›› សំណាងបាន ឆ្លើយ‹‹បាទ អ្នកគ្រូ! ខ្ញុំមិនចូលចិត្តទេ ហើយក៏មិនចង់ឃើញសំរាមមាននៅគ្រប់ទីកន្លែងដែរ››។ អ្នកគ្រូសួរបន្ត ‹‹នៅពេលដែលកូនៗ បានឃើញសំរាមតាមដងផ្លូវ តើកូនៗគួរធ្វើដូចម្តេច?›› សំណាងបានឆ្លើយ ‹‹ពួកយើងត្រូវតែរើសវាចោលក្នុងធុងសំរាម››។



និយាយរួចសំណាងក៏បានមើលទៅមុខវ៉ាយុទ្ធហាក់បីដូចជាដឹងខ្លួនខុសថា
មិនគួរនិយាយបង្អាប់មិត្តបែបហ្នឹងនោះទេ។



ពេលចេញលេង សំណាងក៏បាននិយាយទៅកាន់វ៉ាយុទ្ធ ‹‹ វ៉ាយុទ្ធហ៊ា
ឱ្យខ្ញុំសុំទោសណាដែលនិយាយមិនល្អដាក់ឯង ››។



វ៉ាយុទ្ធក៏មិនបានខឹងនឹងសំណាងដែរ។

ពួកគេតែងតែលេងជាមួយគ្នាយ៉ាងសប្បាយរីករាយនៅសាលារៀន។



មិនយូរប៉ុន្មាន តាមផ្លូវទៅសាលារៀនមិនឃើញមានសំរាមដូចមុនទៀតទេ។
រ៉ាយុទ្ធសប្បាយចិត្តវិញហើយ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(**R4C**)គឺជាអង្គការដែលមិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការ**R4C**កំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការ(**R4C**)បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបង្រៀន៖ https://rermork.org/

មូលនិធិផ្តល់ដោយអង្គការ**TukTuk** និងអង្គការសមាគមន៍រ៉ូតារីក្លឹប។

ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(**R4C**) ដែលបានបង្កើតសៀវភៅនេះឡើងដោយក្តីមេត្តាធម៌។

ទទួលបានព័ត៌មានបន្ថែម

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន